**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អគ្គនាយកដ្ឋានសំណង់**

លេខ : ០៤១ អសណ/នសណ

ថ្ងៃពុធ ៤ កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២១

# លិខិតអនុញ្ញាតបើកការដ្ឋានសំណង់

**យោង**:
- ព្រះរាជក្រមលេខ នស/រកម១១១៩/១៩ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសំណង់
- អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២០ ស្ដីពីលិខិតអនុញ្ញាតសាងសង់
- ប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្ដីពីការគ្រប់គ្រងការដ្ឋានសំណង់
- សេចក្ដីណែនាំលេខ ០០២ ដនស/សណន ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០២០ ស្ដីពីការពង្រឹងគុណភាព និងសុវត្ថិភាពសំណង់
- ពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ ចុះថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០២១ របស់លោក **ក្វយ ឡេសាន**
- កំណត់ហេតុស្ដីពីការចុះពិនិត្យជាក់ស្ដែងដល់ការដ្ឋានសាងសង់លេខ ០១៨ បត/ន.សណ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០២១ របស់ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យ នៃនាយកដ្ឋានសំណង់

**អគ្គនាយក**

**នៃអគ្គនាយកដ្ឋានសំណង់**

អនុញ្ញាតឱ្យលោក **ក្វយ ឡេសាន បើកការដ្ឋានសំណង់** អគារស្នាក់នៅរួម ចំនួន ០១ អគារ កម្ពស់អតិបរមា ៨៨,២០ ម៉ែត្រ មានជាន់ផ្ទាល់ដី ជាន់ទី ០១ ដល់ជាន់ទី ២៥ និងដំបូលទែរ៉ាស់ មានផ្ទៃក្រឡាសំណង់សរុប **២១.១៦៤,២៥ ម៉ែត្រក្រឡា** នៅលើដីឡូត៍ទំហំ **១.១៧៩,០០ ម៉ែត្រក្រឡា** មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៨០១០៤-៦៤៩៩ ផ្លូវលេខ ១៩៣២ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ដែល÷

- មានលិខិតអនុញ្ញាតសាងសង់លេខ ៤៦១ ដនស/អដន ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០២០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មានគម្រោងប្លង់ស្ថាបត្យកម្មសិក្សាដោយ **គង់ ប៉ូច**
- មានប្លង់គ្រឿងផ្គុំសំណង់គណនាដោយលោក **ទូច សុខហេង**
- ទទួលសាងសង់ដោយ BRANCH OF SINOHYDRO CORPORATION LIMITED មានវិញ្ញាបនបត្រលេខ ២៧៧ ប្រក.ដនស/អសណ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០២០
- មានវិស្វករប្រចាំការដ្ឋានឈ្មោះ **ក្រុង លីសុភ័ក្រ្តា**
- មានវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវក្នុងការដ្ឋានដោយក្រុមហ៊ុន FORTE INSURANCE (CAMBODIA) PLC

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

ប៉ុន្តែម្ចាស់សំណង់ត្រូវគោរព និងបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ត្រូវមានសៀវភៅកត់ត្រាអំពីសកម្មភាពសាងសង់ជាប្រចាំ និងត្រូវតម្កល់ទុកក្នុងការដ្ឋានសម្រាប់មន្ត្រីត្រួតពិនិត្យសំណង់
- ត្រូវអនុវត្តការងារសាងសង់ឱ្យបានត្រឹមត្រូវតាមគម្រោងប្លង់ស្ថាបត្យកម្ម និងលក្ខខណ្ឌដូចមានចែងក្នុងលិខិតអនុញ្ញាតសាងសង់ ដែលបានទទួលពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ត្រូវអនុវត្តការងារសាងសង់តាមប្លង់គ្រឿងផ្គុំសំណង់ដែលគណនា និងទទួលខុសត្រូវដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលបានចុះបញ្ជីប្រកបអាជីវកម្មនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមបទប្បញ្ញត្តិបច្ចេកទេសជាធរមាន
- ត្រូវពិនិត្យរកទីតាំងសមស្របក្នុងការតម្លើងប៉មស្ទូចសម្រាប់យោងសម្ភារសំណង់ (ក្នុងករណីដែលមាន) ដោយមិនអនុញ្ញាតឱ្យប្រើប្រាស់ទីធ្លាសាធារណៈ
- ត្រូវរៀបចំប្រព័ន្ធសុវត្ថិភាពការដ្ឋានឱ្យបានត្រឹមត្រូវតាមប្រកាសលេខ ៣២ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមប្លង់រៀបចំការដ្ឋានដែលបានសិក្សារួច
- ហាមដាច់ខាតការស្នាក់នៅក្នុងអគារដែលកំពុងសាងសង់ទោះបីជាលក្ខណៈបណ្តោះអាសន្នក៏ដោយ និងហាមដាច់ខាតអ្នកដែលគ្មានភារកិច្ចចូលក្នុងការដ្ឋាន
- ស្នើសុំកែសម្រួលប្លង់ស្ថាបត្យកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីមានការសាងសង់ខុសពីលិខិតអនុញ្ញាតសាងសង់
- អនុវត្តការងារសាងសង់ទៅតាមពេលវេលាដែលបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ដាក់តាំងផ្ទាំងគំនូរសំណង់ ឬ ផ្លាកសញ្ញាផ្សព្វផ្សាយនៅការដ្ឋានសំណង់ដោយគោរពតាមគោលការណ៍ដូចខាងក្រោម ÷
  - ១- អក្សរខ្មែរត្រូវសរសេរឱ្យបានធំជាងអក្សរបរទេស ហើយដាក់នៅជួរខាងលើ
  - ២- អក្សរបរទេសអាចសរសេរនៅខាងក្រោម និងមានទំហំពាក់កណ្តាលនៃអក្សរខ្មែរ
  - ៣- ការសរសេរអក្សរខ្មែរត្រូវអនុវត្តតាមវចនានុក្រមខ្មែររបស់សម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ “**ជួន ណាត**”
- ជូនដំណឹងមកអគ្គនាយកដ្ឋានសំណង់នៅពេល÷
  - ១-ចាប់ផ្តើមការងារជាន់ផ្ទាល់ដី (E0)
  - ២-សាងសង់បានពាក់កណ្តាលនៃគម្រោង
- ស្នើសុំលិខិតបិទការដ្ឋានសាងសង់ពីអគ្គនាយកដ្ឋានសំណង់ នៅពេលសំណង់បញ្ចប់ការងារសាងសង់រួចរាល់។

អគ្គនាយក

អគ្គនាយកដ្ឋានសំណង់

**ឆាន់ សុវណ្ណផល**

**ចម្លងជូន÷**

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-រដ្ឋបាលរាជធានីភ្នំពេញ (ដើម្បីជូនជ្រាប)
-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ (ដើម្បីមុខការ)
-ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**អគ្គនាយកដ្ឋានសំណង់**
លេខ : ០៧២ អសណ/នសណ

ថ្ងៃសុក្រ ១១កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៨ ឆ្នាំ ២០២២

## លិខិតបិទការដ្ឋានសំណង់

**យោង:** - អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតអនុញ្ញាតសាងសង់លេខ ៤៦១ ដនស/អដន ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០២០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់លេខ ០២១ អសណ/នសណ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២១ របស់អគ្គនាយកដ្ឋានសំណង់
- ពាក្យសុំលិខិតបិទការដ្ឋានសំណង់ ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០២២ របស់ម្ចាស់សំណង់
- របាយការណ៍ស្តីពីការចុះត្រួតពិនិត្យការដ្ឋានសំណង់លេខ ០៧៧ បត/ន.សណ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ២០២២ របស់ការិយាល័យបច្ចេកទេស និងត្រួតពិនិត្យ នៃនាយកដ្ឋានសំណង់

**អគ្គនាយក**
**នៃអគ្គនាយកដ្ឋានសំណង់**

ផ្តល់ជូនលោក **ភួយ ឡេសាន** ជាម្ចាស់សំណើសុំបិទការដ្ឋានសំណង់អគារស្នាក់នៅរួម ចំនួន ០១ អគារ កម្ពស់អតិបរមា ៨៨,២០ ម៉ែត្រ មានជាន់ផ្ទាល់ដី ជាន់ទី ០១ ដល់ជាន់ទី ២៥ និងដំបូលទែរ៉ាស់ មានផ្ទៃក្រឡាសំណង់សរុប **២១.១៦៤,២៥ ម៉ែត្រក្រឡា** នៅលើដីឡូត៍ទំហំ **១.១៧៩,០០ ម៉ែត្រក្រឡា** មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៨០១០៤-៦៤៩៩ ផ្លូវលេខ ១៩៣២ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ នូវ **លិខិតបិទការដ្ឋានសំណង់** ជាផ្លូវការចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ក្នុងករណីម្ចាស់សំណង់មានការកែសម្រួលមុខងារអគារ សោភ័ណភាព ឬសាងសង់បន្ថែមផ្សេងទៀត ត្រូវបំពេញបែបបទស្នើសុំការអនុញ្ញាតជាមុនពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**អគ្គនាយក**

អគ្គនាយកដ្ឋានសំណង់

**ឆាន់ សុវុទ្ធផល**

**ចម្លងជូន :**
- ខុទ្ទកាល័យ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**
- រដ្ឋបាលរាជធានីភ្នំពេញ (ដើម្បីជូនជ្រាប)
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ